CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សន្ទស្សន៍ចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ ២០០៩ លេខ ០៥

## ការការពារប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ – ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ: ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល ដើម្បីជួយទ្រទ្រង់មូលដ្ឋានផលិតកម្មនៅកម្ពុជា[១]

"ឧស្សាហូបនីយកម្ម គឺជាកត្តាគន្លឹះសំរាប់ជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មី ។"

*លោក Stephen Higgins អគ្គនាយក នៃធនាគារ ANZ Royal*

"ដើម្បីផ្តល់ថាមពលជួយទ្រទ្រង់ដល់មូលដ្ឋានផលិតកម្ម កម្ពុជាត្រូវតែសំរេចគោលដៅសំខាន់ៗបួន ឱ្យបាន គឺ: ការផ្គត់ផ្គង់គ្រប់គ្រាន់ លទ្ធភាពទទួលបានការផ្គត់ផ្គង់ ការផ្គត់ផ្គង់មានគុណភាពល្អនិងទៀងទាត់អាចទុកចិត្តបាន ហើយនិង ការយកថ្លៃសមរម្យលើការផ្គត់ផ្គង់ ។"

*ប្រសាសន៍របស់ ឯកឧត្តម បណ្ឌិត ទី នរិទ្ធ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា នៅក្នុងសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

### វិបត្តិសាកល និងវិស័យផលិតកម្មនៅកម្ពុជា: ផលប៉ះពាល់ និងការខ្វះចន្លោះ

ឧស្សាហកម្ម ជាវិស័យលូតលាស់លឿនជាងគេនៅកម្ពុជាក្នុងមួយទសវត្សរ៍កន្លងទៅនេះ ។ ការរួមចំណែករបស់ វិស័យនេះ នៅក្នុង ផសស កើនឡើងស្ទើរមួយជាពីរ ពី ១៧% នៅឆ្នាំ១៩៩៨ ដល់ ៣០% នៅឆ្នាំ២០០៧ ។ កំណើននេះជំរុញជាសំខាន់ដោយផ្នែកផលិតកម្ម និង សំណង់ ។

កំលាំងស្នូលរបស់ឧស្សាហកម្មផលិតកម្មនៅកម្ពុជាគឺ វិស័យកាត់ដេរ ។ សំលៀកបំពាក់តំណាងឲ្យប្រហែលជា ពាក់កណ្តាលនៃផលិតផលឧស្សាហកម្មបច្ចុប្បន្ន ហើយសព្វថ្ងៃ ផលិតភាពពលកម្មក្នុងវិស័យនេះ មានកំរិតស្មើគ្នានឹងប្រទេសវៀតណាម ដែលបង្ហាញថា ប្រទេសកម្ពុជាអាចបង្កើនសមត្ថភាពដើម្បីប្រកួតប្រជែង នៅក្នុងតំបន់បាន ។ ឧស្សាហកម្មកាត់ដេរ ប្រើប្រាស់ប្រហែលតែ ១៣% នៃកំលាំងពលកម្មប៉ុណ្ណោះ ធៀបនឹង ៥៩% សំរាប់វិស័យកសិកម្មដែលរួមចំណែកបានតិចជាង នៅក្នុង ផសស ។ ផលិតកម្មម្ហូបអាហារ មានមិនដល់ ១០% ទេ ក្នុងផលិតកម្មឧស្សាហកម្មនៅកម្ពុជា ។

ឧស្សាហូបនីយកម្ម ជាកត្តាគន្លឹះជំរុញឲ្យសេដ្ឋកិច្ចកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មី គឺដូចគ្នានឹងប្រទេសឯទៀតៗ ដូចជា ថៃ ជាដើម ដែលវាធ្លាប់ជំរុញឲ្យសំរេចបានការអភិវឌ្ឍមួយកំរិតខ្ពស់ថែមទៀត ។ ដំណើរការធ្វើទំនើបកម្មនៅថៃ បានចាប់ផ្តើមនៅចុងទសវត្សរ៍១៩៥០ ហើយប្រាក់ចំណូលក្នុងមនុស្សម្នាក់ កើនឡើងពី ១០០ដុល្លារUS រហូតដល់ប្រហែល ៣០០០ដុល្លារUS ក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ឧស្សាហកម្មផលិតកម្ម ដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនេះ ដោយចំណែករបស់វានៅក្នុង ផសស កើនច្រើនជាងមុនមួយជាបី ។ ផលិតកម្មថៃ បានចាប់ផ្តើមពីឧស្សាហកម្មវាយនភណ្ឌអតិពលកម្ម ដែលបន្ទាប់មក បានជួយជំរុញ និងទាក់ទាញផលិតកម្មឧស្សាហកម្មធុនស្រាលជាច្រើន ។ កំណើនប្រាក់ចំណូល និងតំរូវការរបស់អ្នកប្រើប្រាស់ បានជួយពន្លឿនការផ្លាស់ប្តូរមុខមាត់ថ្មីនេះ ។ កម្ពុជា

---

[១] អត្ថបទនេះ ជាការបូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗក្នុងវគ្គទី៣ខ (១) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។ វាគ្មិនក្នុងវគ្គនេះគឺមានឯកឧត្តម បណ្ឌិត ទី នរិទ្ធ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា និង លោក Stephen Higgins អគ្គនាយក នៃធនាគារ ANZ Royal ។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

### ក្រាហ្វិក ១: ការរួមចំណែកក្នុង ផសស នៃឧស្សាហកម្ម (ជាភាគរយ)




ប្រភព: បទបង្ហាញរបស់ធនាគារពិភពលោក និង *Breisinger* និង *Diao* នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩

ប្រហែលអាចរៀនសូត្របានខ្លះដែរ ពីបទពិសោធន៍ដូចខាងលើ ។ ទោះបីការរួមចំណែករបស់ឧស្សាហកម្ម នៅក្នុង ផសស នៅកម្ពុជា បានកើនឡើងយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំនេះក៏ដោយ ក៏វានៅតែខ្សោយជាងប្រទេសជិតខាង គឺ ថៃ និង វៀតណាម ដែរ (ក្រាហ្វិក ១) ។

សំលៀកបំពាក់ គឺជា ផលិតផលនាំចេញឈានមុខគេរបស់កម្ពុជា ដែលរួមចំណែកដល់ទៅ ៧០–៨០% នៃការនាំចេញសរុប នៅមុនពេលវិបត្តិសាកលកើតមានឡើង ។ វិស័យកាត់ដេរដែលពឹងផ្អែកខ្លាំង ទៅលើទីផ្សារនាំចេញតែមួយ គឺ សហរដ្ឋអាមេរិក បែបនេះ វាងាយរងគ្រោះណាស់ពីវិបត្តិសេដ្ឋកិច្ចសាកល ។ ការធ្លាក់ចុះយ៉ាងលឿននៃការលក់រាយនៅសហរដ្ឋអាមេរិកដោយសារវិបត្តិ បានជះឥទ្ធិពលដោយផ្ទាល់ទៅលើ ការនាំចេញផ្សេងៗទៅកាន់ប្រទេសមហាអំណាចសេដ្ឋកិច្ចនេះ (ក្រាហ្វិក ២) ។ នៅចុងឆ្នាំ២០០៨ ការនាំចេញសំលៀកបំពាក់ឡើងដល់ ២,៩ពាន់លានដុល្លារ*US* ឬ ៦៥% នៃការនាំចេញសរុប ដោយសារកំណើនបរិមាណនាំចេញពីមួយឆ្នាំទៅមួយឆ្នាំ បានថយចុះយ៉ាងខ្លាំង នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។ នៅខែកុម្ភៈ ២០០៩ តំលៃការនាំចេញជាមធ្យម បានធ្លាក់ចុះគួរឲ្យបារម្ភ មកត្រឹម ១០២លានដុល្លារ*US* ធៀបនឹងតំលៃជាមធ្យមប្រចាំខែ ២០០លានដុល្លារ*US* នៅឆ្នាំ២០០៨ ។ ការធ្លាក់ចុះនេះ មានន័យថា ការបាត់បង់ការងារ និងភាពគ្មានការងារធ្វើពេញលេញ វាកើនឡើង ពីព្រោះរោងចក្រមួយចំនួនបានបិទទ្វារ ឬ បានកាត់បន្ថយចំណាយប្រតិបត្តិការ ។

ការវិភាគលំអិតបង្ហាញថា កង្វះចំរុះកម្មក្នុងឧស្សាហកម្មផលិតកម្មនៅកម្ពុជា បានបង្កើនភាពងាយរងគ្រោះ ពីវិបត្តិសាកល និងរារាំងដល់ការរីកដុះដាល និងកំណើនផ្នែកនាំចេញ ។ បញ្ហាមួយទៀត គឺ សកម្មភាពផលិតកម្មភាគច្រើនស្ថិតក្នុងផ្នែកមានតំលៃបន្ថែមតិច ។ ឧទាហរណ៍ ផ្នែកកាត់ដេរមិនទាន់លូតលាស់ហួសពីការងារកាត់ និងដេរតើរីមធម្មតា ទៅផលិតទំនិញពិបាកធ្វើជាងនេះដែលមានតំលៃបន្ថែមច្រើននោះទេ ។

បញ្ហាចោទខាងហេដ្ឋារចនាសម្ព័ន្ធ ក៏បានរារាំងដល់ការរីកលូតលាស់ដែរ ជាពិសេស ថាមពលអគ្គិសនី និង ការដឹកជញ្ជូន ដែលជាបញ្ហាប្រឈមធំៗបំផុតចំពោះឧស្សាហូបនីយកម្មនៅកម្ពុជា ។

ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជា កំពុងជួបបញ្ហា កង្វះថាមពលផ្គត់ផ្គង់ កង្វះលទ្ធភាពទទួលបាន និងភាពមិនទៀងទាត់នៃការផ្គត់ផ្គង់ តំលៃអគ្គិសនីខ្ពស់ និង កង្វះហិរញ្ញប្បទាន:

- **កង្វះថាមពលផ្គត់ផ្គង់:** សមត្ថភាពផលិតថាមពលអគ្គិសនីនាបច្ចុប្បន្ន មិនគ្រប់គ្រាន់សំរាប់បំពេញ តំរូវការប្រើប្រាស់ដែលគេប៉ាន់ស្មានថា បានកើនឡើង ២០–២៦% ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះទេ ។ ការផលិតថាមពលអគ្គិសនី ពឹងផ្អែកលើឥន្ធនៈនាំចូលពីប្រទេសក្រៅ ដូច្នេះការផ្គត់ផ្គង់ មានភាពមិនសូវប្រាកដប្រជា និងមានបន្ទុកចំណាយខ្ពស់ ។ កម្ពុជា មានសក្តានុភាពខាងវារីអគ្គិសនី ប៉ុន្តែមិនអាចទុកចិត្តបានល្អទេ ដោយសារភ្លៀងធ្លាក់មិនទៀងទាត់ ហើយទឹកមានចំនួនតិចនៅរដូវប្រាំង ។ ម្យ៉ាងទៀត កម្ពុជាក៏ខ្វះខាតប្រភពថាមពលផ្សេងទៀត ដូចជា ធ្យូងថ្ម និង ឧស្ម័នធម្មជាតិដែរ។
- **កង្វះលទ្ធភាពទទួលបាន និងភាពមិនទៀងទាត់នៃការផ្គត់ផ្គង់:** កម្ពុជាត្រូវវិនិយោគច្រើនខ្លាំងណាស់ ក្នុងការកសាងប្រព័ន្ធបញ្ជូននិងចែកចាយ ដើម្បីឲ្យថាមពលអគ្គិសនីបានទៅដល់ កន្លែងត្រូវការប្រើប្រាស់ យ៉ាងទៀងទាត់ និងគួរទុកចិត្តបាន ។

### ក្រាហ្វិក ២: ការនាំចេញសំលៀកបំពាក់របស់កម្ពុជា និងការលក់រាយនៅសហរដ្ឋអាមេរិក (កំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




ប្រភព: បទបង្ហាញរបស់តំណាង *IMF* នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩

### ក្រាហ្វិក ៣: តំលៃអគ្គិសនីក្នុង ១គីឡូវ៉ាត់ម៉ោង (សេន)




ប្រភព: បទបង្ហាញរបស់តំណាងធនាគារពិភពលោក នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩

- **តំលៃអគ្គិសនីខ្ពស់:** គេកត់សំគាល់ឃើញថា តំលៃដ៏ខ្ពស់នៃអគ្គិសនីនៅកម្ពុជា គឺជាឧបសគ្គចំបងមួយចំពោះកំណើន (ក្រាហ្វិក ៣) ។ យោងតាមធនាគារពិភពលោក តំលៃអគ្គិសនីនៅកម្ពុជា ប្រែប្រួលពី ០,១៨ដុល្លារUS នៅតាមទីក្រុង រហូតដល់ ០,៣០-០,៩០ដុល្លារUS នៅទីជនបទ គឺខ្ពស់ខ្លាំងណាស់ធៀបនឹងប្រទេសជិតខាងដែលសុទ្ធតែមានតំលៃក្រោម ០,១០ដុល្លារUS ។ តំលៃខ្ពស់នេះ អាចមើលឃើញច្បាស់ ដោយសារសហគ្រាសជាច្រើនចូលចិត្តប្រើម៉ាស៊ីនភ្លើងជំនួសវិញ ។ គេប៉ាន់ស្មានថា សហគ្រាសនានានៅកម្ពុជា ផលិតប្រហែល ៣៦% នៃតំរូវការអគ្គិសនីរបស់ខ្លួនដោយប្រើម៉ាស៊ីនភ្លើង ហើយចំណាយលើប្រេងម៉ាស៊ូតមានចំណែកប្រហែល ២០% នៃចំណាយប្រតិបត្តិការនៅតាមសណ្ឋាគារមួយចំនួន ។ ក្រៅពីតំលៃដ៏ខ្ពស់នៃធាតុចូល និងការផលិតថាមពលតាមរបៀបដាច់ដោយដុំ មូលហេតុមួយទៀតនៃអគ្គិសនីមានតំលៃខ្ពស់ គឺកង្វះប្រសិទ្ធភាពក្នុងប្រតិបត្តិការ ដែលនាំឲ្យបាត់បង់ថាមពលអគ្គិសនីយ៉ាងច្រើន ក្នុងការបញ្ជូន និងចែកចាយ ។ គេប៉ាន់ស្មានថា ពីឆ្នាំ១៩៩៨ ដល់ ២០០៨ មានការបាត់បង់ថាមពលអគ្គិសនីប្រហែល ១០,៧% ហើយកាលពីមុននោះទៀត តួលេខបាត់បង់គឺ ប្រហែល ២៨%-៣០% ។
- **កង្វះហិរញ្ញប្បទាន:** គំរោងធំៗ ត្រូវការទុនយ៉ាងច្រើនដែលពិបាកនឹងរកបាន ។ សព្វថ្ងៃកំពុងមានការស្នើសុំជំនួយឧបត្ថម្ភច្រើនថែមទៀតពីសំណាក់អ្នកផ្តល់ជំនួយ ។

## ក្រាហ្វិក ៤: ចំណាយដឹកជញ្ជូនផលិតផលកសិកម្ម




ប្រភព: បទបង្ហាញរបស់តំណាងធនាគារពិភពលោក នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩

## ក្រាហ្វិក ៥: ផ្លូវថ្នល់ចាក់កៅស៊ូ




ប្រភព: បទបង្ហាញរបស់តំណាងធនាគារពិភពលោក នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩

ការដឹកជញ្ជូនផលិតផលកសិកម្មនៅកម្ពុជា មានតំលៃខ្ពស់ បើធៀបនឹងប្រទេសថៃ និងវៀតណាម (១៥ដុល្លារUS/តោន ក្នុងចំងាយ ១០០គីឡូម៉ែត្រ នៅកម្ពុជា ធៀបនឹង ៧,៥ដុល្លារUS នៅវៀតណាម និង ត្រឹមតែ ៤ដុល្លារUS នៅថៃ) (ក្រាហ្វិក ៤) ។ បញ្ហានេះមានមូលហេតុជាច្រើន ដូចជា បណ្តាញផ្លូវថ្នល់អន់ខ្សោយជាដើម ។ ផ្លូវថ្នល់នៅកម្ពុជា មានស្ថានភាពអាក្រក់ជាង ផ្លូវថ្នល់នៅថៃ និងវៀតណាម ។ យោងតាមធនាគារពិភពលោក ផ្លូវថ្នល់ចាក់កៅស៊ូនៅកម្ពុជា មានតែ ៦,៣% ប៉ុណ្ណោះ ធៀបនឹង ២៥% នៅវៀតណាម និង ៩៨% នៅថៃ (ក្រាហ្វិក ៥) ។

សំរាប់រយៈពេលមធ្យម គេគួរមានទស្សនសុទិដ្ឋិនិយម ពីព្រោះសព្វថ្ងៃផែនការធំៗមួយចំនួនរបស់រដ្ឋាភិបាល កំពុងដាក់អនុវត្ត ដើម្បីដោះស្រាយបញ្ហាខាងលើ ។

ប្រព័ន្ធផ្លូវធំៗ (ផ្លូវជាតិ) បានកែលំអជិតរួចរាល់ហើយ ហើយផ្លូវថ្នល់បន្ទាប់បន្សំ (ផ្លូវខេត្ត) ក៏កំពុងចាក់កៅស៊ូជាបណ្តើរៗ ។ គំរោងវារីអគ្គិសនីចំនួន៣ កំពុងដំណើរការសាងសង់ ការតភ្ជាប់បណ្តាញជាមួយប្រទេសវៀតណាម និងថៃ កំពុងកើនឡើងទៀត ហើយបណ្តាញផ្គត់ផ្គង់អគ្គិសនី ក៏កំពុងកែលំអដូចរៀបរាប់ខាងក្រោម ។

នាបច្ចុប្បន្ន រដ្ឋាភិបាលកំពុងកែលំអបណ្តាញអគ្គិសនី តាមផែនការ "ប្រព័ន្ធអភិវឌ្ឍន៍អគ្គិសនីកម្ពុជា ឆ្នាំ២០១៣-២០១៨" ។ ក្នុងផែនការនេះ បណ្តាញបញ្ជូនអគ្គិសនីជាតិមួយមានកម្លាំងវ៉ុលខ្ពស់ នឹងត្រូវកសាងឡើង ហើយតភ្ជាប់មកភ្នំពេញ ដើម្បីដាក់បញ្ចូលទីផ្សារទាំងអស់មកជាមួយគ្នា ។ បណ្តាញនេះ នឹងត្រូវតភ្ជាប់ទៅទំនប់វារីអគ្គិសនីទាំងអស់ដែលមានស្រាប់ និងទំនប់ដែលត្រូវកសាងទៅអនាគត ។ ក្នុងដំណាក់កាលបន្ទាប់នៃផែនការ គេនឹងផ្តោតលើការនាំចូលអគ្គិសនីមកពីប្រទេសវៀតណាម និងថៃ ។

## វិបត្តិ និង មធ្យោបាយឆ្ពោះទៅមុខ: ចក្ខុវិស័យ និង ទិសដៅគោលនយោបាយទៅអនាគត

ឧស្សាហកម្មផលិតកម្មកម្ពុជា មានសក្តានុពល និងឱកាសល្អជាច្រើន ដូចជា ទីតាំងភូមិសាស្ត្រដ៏ល្អនៃប្រទេសកម្ពុជា ជាដើម ។ ដូច្នេះ នៅពេលផ្លូវដែកតភ្ជាប់ទៅវៀតណាម និងថៃ បានស្តាបនា និងជួសជុលរួចរាល់ ឬក៏ នៅពេលផ្លូវដែកតភ្ជាប់តំបន់អាស៊ាន (*Trans-Asian Railway*) បានចេញជាផ្លែផ្កា ទីតាំងដ៏ល្អរបស់កម្ពុជានៅចំកណ្តាលតំបន់ ដែលមានសន្ទុះសេដ្ឋកិច្ចដ៏ខ្លាំងបំផុតមួយក្នុងពិភពលោក នឹងផ្តល់ឱកាសប្រសើរខ្លាំងណាស់សំរាប់ ពាណិជ្ជកម្មផលិតផលឧស្សាហកម្ម ។

សក្តានុពលនៃឧស្សាហកម្មផលិតកម្ម ក៏អាចវាយតំលៃបានតាមរយៈកសិកម្មដែរ ដែលជាវិស័យមានការប្រមូលផ្តុំ កំលាំងពលកម្មកម្ពុជាមួយភាគធំ ។ ពិតហើយ កសិកម្មគឺជាវិស័យគន្លឹះដែលត្រូវជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងប៉ុន្មានឆ្នាំខាងមុខ ប៉ុន្តែរឿងនេះអាចសំរេចបានតាមរយៈការកែលំអវិធីដាំដុះ និង

កំណើនការប្រើប្រាស់គ្រឿងយន្ត ។ តាមនេះ នឹងមានការថយចុះភាគរយប្រជាជនដែលធ្វើការដោយផ្ទាល់ក្នុងកសិកម្ម ហើយកំលាំងពលកម្មកាន់តែច្រើនឡើងនឹងបែរទៅខាងឧស្សាហកម្មផលិតកម្មវិញ ។ ដូច្នេះដំណើរការនេះ ដាក់សំពាធឲ្យគេប្រឹងប្រែងអភិវឌ្ឍន៍ឧស្សាហកម្មផលិតកម្ម ។

វិបត្តិសាកល បានបង្ហាញពីគ្រោះថ្នាក់នៃការពឹងផ្អែកខ្លាំងពេកទៅលើតែផ្នែកណាមួយនៃឧស្សាហកម្ម ។ ដូចនេះ គោលនយោបាយឧស្សាហកម្ម ត្រូវតែបង្វែរទិសទៅផ្តោតលើការធ្វើចំរុះកម្មផលិតកម្ម ឲ្យបានច្រើនមុខលើសពីការកាត់ដេរនេះទៀត ។ ផលិតកម្មម្ហូបអាហារ ក៏ផ្តល់ឱកាសល្អមួយដែរ ពីព្រោះសព្វថ្ងៃ ផលិតផលកសិកម្មក្នុងស្រុក ដែលមិនទាន់កែច្នៃភាគច្រើន ត្រូវគេនាំចេញទៅប្រទេសជិតខាង ដើម្បីធ្វើការកែច្នៃ ។ បន្ទាប់មក កម្ពុជាក៏ត្រូវនាំចូលមកវិញនូវផលិតផលដែលកែច្នៃហើយនេះ ។

បញ្ហាចោទខាងថាមពលអគ្គិសនី និងការដឹកជញ្ជូន គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរចំពោះកំណើន ។ ដូច្នេះ យុទ្ធសាស្រ្ត សំដៅដោះស្រាយបញ្ហាទាំងនោះ ត្រូវដាក់អនុវត្តភ្លាមៗ ដោយមិនបង្អង់ ហើយកិច្ចប្រឹងប្រែងទាក់ទាញ ដៃគូសហការណ៍សាធារណៈ-ឯកជន ក្នុងគំរោងផ្សេងៗខាងដឹកជញ្ជូន និងថាមពល ត្រូវតែបង្កើនឡើងទ្វេដង ។ រដ្ឋាភិបាល ក៏ត្រូវបន្តស្នើសុំជំនួយឧបត្ថម្ភសំរាប់សហគ្រាស អគ្គិសនីកម្ពុជា (EDC) ផងដែរ ។

ប្រព័ន្ធអភិវឌ្ឍន៍អគ្គិសនីកម្ពុជា គឺជាផែនការដ៏សំខាន់មួយ សំដៅបង្កើនការផ្គត់ផ្គង់ថាមពលអគ្គិសនី កែលំអការទទួលបានអគ្គិសនីប្រើប្រាស់ ភាពទៀងទាត់គួរទុកចិត្តបាននៃការផ្គត់ផ្គង់ ព្រមទាំង ជួយបញ្ចុះតំលៃអគ្គិសនី ។ គេរំពឹងថានៅប៉ុន្មានឆ្នាំខាងមុខ បណ្តាញអគ្គិសនីជាតិនឹងមានតភ្ជាប់ទៅគ្រប់ស្ថានីយវារីអគ្គិសនី ដែលបានកសាងឡើង ហើយ សមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនី នឹងកើនឡើងយ៉ាងច្រើន នៅតាមតំបន់ដែលមានដាក់អនុស្ថានីយនៃបណ្តាញអគ្គិសនី ។ ឧស្សាហកម្មចំបងៗនិង តំបន់សេដ្ឋកិច្ចពិសេសៗដែលស្ថិតក្នុងរង្វង់១០គីឡូម៉ែត្រអំពីអនុស្ថានីយ ក៏អាចទទួលបានការផ្គត់ផ្គង់តាមរយៈខ្សែកាបតចូលដោយផ្ទាល់ដោយមានតំលៃថោក ។ ឧស្សាហកម្ម ដែលប្រើម៉ាស៊ីនភ្លើងចាក់ម៉ាស៊ូត ក៏អាចបែរមកតភ្ជាប់យកថាមពលអគ្គិសនីពីបណ្តាញផ្គត់ផ្គង់ ដែលមានតំលៃថោកជាងដែរ ។

មានវិធានការផ្សេងៗជាច្រើនទៀត ដែលអាចអនុវត្តបាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ ដូចជា ការអភិវឌ្ឍប្រភពថាមពលថោកជាងមុន និង ការបង្កើនប្រសិទ្ធភាពប្រតិបត្តិការដែលតំរូវឲ្យមានការកែលំអ អភិបាលកិច្ចក្នុងផ្នែកនេះការប្រកួតប្រជែង សេរីភាវូបនីយកម្មទីផ្សារ បទប្បញ្ញត្តិឯករាជ្យ និង ការកំណត់ថ្លៃផ្អែកលើទីផ្សារ ។

មានបញ្ហាប្រឈមធ្ងន់ធ្ងរដទៃទៀត ដែលរារាំងដល់កំណើនផលិតកម្ម និងដែលត្រូវដោះស្រាយ ។ បញ្ហាទាំងនោះ រួមមាន :

- **ការពង្រឹងអនុវត្តន៍កិច្ចសន្យា:** ការងារនេះសំខាន់ណាស់ ជាពិសេសចំពោះវិនិយោគិនបរទេស និងធនាគារ ។ ការបង្កើតតុលាការពាណិជ្ជកម្ម ដែលមានចៅក្រមប្រកបដោយគុណភាពខ្ពស់ ក៏សំខាន់ខ្លាំងណាស់ដែរ ។
- **ការវិនិយោគច្រើនថែមទៀតលើការបណ្តុះបណ្តាលវិជ្ជាជីវៈ:** កម្មករដែលមានចំនួនកាន់តែច្រើន និងមានការបណ្តុះបណ្តាលកាន់តែល្អ នឹងជួយសំរួលដល់ការពង្រីកវិស័យឧស្សាហកម្ម ។
- **ការជៀសវាងប្រើប្រាស់គ្រឿងលើកទឹកចិត្តខាងពន្ធដារ:** វិនិយោគិនរយៈពេលវែង និងមានកេរ្តិ៍ឈ្មោះល្អ តែងផ្តល់តំលៃដល់ហេដ្ឋារចនាសម្ព័ន្ធមានគុណភាពល្អ ជាជាង គ្រឿងលើកទឹកចិត្តខាងពន្ធដារ ។ ការផ្តល់គ្រឿងលើកទឹកចិត្តខាងពន្ធដារ ត្រូវកាត់បន្ថយជាអតិបរមា ពីព្រោះប្រាក់ពន្ធដែលបានលះបង់ វាមានប្រយោជន៍ជាងបើសិនយកវាទៅចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ។ ម្យ៉ាងទៀត បណ្តាក្រុមហ៊ុនដែលមានការទាក់ទាញខ្លាំងដោយសារ គ្រឿងលើកទឹកចិត្តខាងពន្ធដារ ច្រើនតែចាកចេញទៅវិញភ្លាមនៅពេលមានប្រទេសមួយទៀតគេផ្តល់ សម្បទានពន្ធល្អជាង ។
- **កាត់បន្ថយចំណាយក្រៅផ្លូវការលើការវិនិយោគ:** ការអង្កេតនាពេលថ្មីៗមួយបានបង្ហាញថា ៥២% នៃសហគ្រាស បានចាត់ទុកអំពើពុករលួយថាជាឧបសគ្គដ៏ចំបងដល់ការវិនិយោគ ។ ទោះជារឿងនេះពិត រឺមិនពិតប៉ុណ្ណក្តី ប៉ុន្តែមតិនេះបានបង្កើតអារម្មណ៍អវិជ្ជមានចំពោះប្រទេសកម្ពុជា ដែលអាចប៉ះពាល់ដល់វិនិយោគផ្ទាល់ពីបរទេស និងដែលត្រូវតែដោះស្រាយ ។

ការរៀបចំសេដ្ឋកិច្ចឡើងវិញ ដោយផ្តល់តួនាទីធំជាងមុនដល់ផ្នែកផលិតកម្ម អាចជួយរុញច្រានប្រទេសកម្ពុជា ឲ្យសំរេចបានការអភិវឌ្ឍន៍មួយកំរិតខ្ពស់ថែមទៀត ។ គោលគំនិតថា ចំរុះកម្ម និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងថាមពលជាលក្ខខណ្ឌចាំបាច់សំរាប់ឲ្យកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មី វាគ្មានអ្វីថ្មីប្លែកទេ ។ ប៉ុន្តែដោយសារ ការងារនេះធំធេង និងត្រូវការហិរញ្ញប្បទានច្រើន ដូច្នេះត្រូវមានសកម្មភាពរួមគ្នារវាងរដ្ឋាភិបាល និង ដៃគូសហការអភិវឌ្ឍន៍ ជាពិសេស នៅពេលមានវិបត្តិបែបនេះ ដែលធ្វើឲ្យប្រទេសជាតិត្រូវជួបកង្វះខាតខាងធនធាន ។

**CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh, website: http://www.cdri.org.kh